សមាទបិត គុ. [សំ+អា+ទា+ណាបេ+ត] ដែល...ដឹកនាំហើយ, ...បបួលហើយ ។

សមាទបេតិ កិ. [សំ+អា+ទា+ណាបេ+តិ.វ.] ដឹកនាំ, បបួល ។

សមាទាយ អ. [សំ+អា+ទា+ត្វា] កាន់យកព្រមហើយ, សមាទានហើយ ។

សមាទិយឹសុ កិ. [សំ+អា+ទា+ណាយ+ឩំ.អជ្ជ.] កាន់យកព្រមហើយ, សមាទានហើយ ។

សមាធិ ពុំ. [សំ+អា+ធា+ឥ] កិ.តាំងចិត្តនឹងនួន, កិ.តម្កល់ចិត្តដោយប្រពៃ; វ. សំ សុដ្ឋុ អាធានំ> សមាធិ ។

សមាន គុ. [សម+អន] ស្មើ, ស្មើគ្នា ។ <អស+មាន, លុបអ = កាលមាន ។

សមាបជ្ជិ កិ. [សំ+អា+បទ+យ+ឦ.អជ្ជ.] ដល់ព្រមហើយ, ចូលហើយ ។

សមាបត្តិ ឥ. [សំ+អា+បទ+តិ] ធម្មជាតិដែល...គប្បីចូល (សមាបត្តិ); វ. សមាបជ្ជិតព្វាតិ> សមាបត្តិ ។ -វុដ្ឋិត គុ. ដែលចេញហើយចាកសមាបត្តិ, ...អំពីសមាបត្តិ ។



សមាបន្ន គុ. [សំ+អា+បទ+ត] ដល់ព្រមហើយ, ចូលហើយ ។

សមាហរថ កិ. [សំ+អា+ហរ+អ+ថ.ប.] ចូរនាំមកព្រម, ចូរប្រមូល, ចូរប្រជុំ ។

សមិជ្ឈតិ កិ. [សំ+ឥធ+យ+តិ.វ.] សម្រេច, រមែងសម្រេច ។

សមិជ្ឈន នពុំ. [សំ+ឥធ+យ+យុ] កិ.សម្រេច, សេចក្ដីសម្រេច ។

សមិទ្ធ គុ. [សំ+ឥធ+ត] ដែលសម្រេចហើយ ។

សមិទ្ធិ ឥ. [សំ+ឥធ+តិ] សេចក្ដីសម្រេច, កិ.សម្រេច; វ. សមិជ្ឈនំ> សមិទ្ធិ ។

សមិតត្ត នពុំ. [សមិត+ត្ត] កិ.ភាពនៃបុគ្គលអ្នករម្ងាប់ហើយ ។

សមិតិ ឥ. [សំ+ឥ+តិ] ទីប្រជុំ; វ. សមេយន្តិ ឯត្ថាតិ> សមិតិ ។

សមីប នពុំ. [សំ+អាប, អា>ឦ] ជិត, ជិតជិត ។

សមីរតិ កិ. [សំ+ឦរ+អ+តិ.វ.] រមៀល, រសាត់ ។

សមុគ្គម ពុំ. [សំ+ឧ+គមុ+ណ] កិ.តាំងឡើងព្រម, កិ.កាត់ផ្ដាច់ ។

សមុដ្ឋាយ អ. [សំ+ឧ+ឋា+ត្វា] តាំងឡើងព្រមហើយ, ក្រោកឡើងព្រមហើយ, កើតហើយ, ឆ្លុះឡើងហើយ ។

សមុដ្ឋាបេតុំ កិ. [សំ+ឧ+ឋា+ណាបេ+តុំ.អជ្ជ.] ឱ្យតាំងឡើងព្រមហើយ ។

**សមុដ្ឋិត** គុ. [ សំ+ឧ+ឋា+ត.អា.+ត ] តាំងឡើងព្រមហើយ ។

**សមុទ្ទ** ចុំ. [ សម+ឧទ+ទ ] សមុទ្រ, (វិ. **សមំ ឧទកេន លោឍំ ឯត្ថាតិ> សមុទ្ទោ**) ។

**សមុទាចរតិ** កិ. [ សំ+ឧ+អា+ចរ+អ+តិ.វ., ចុរ៉ទ.អា. ] ប្រព្រឹត្តឡើងព្រម, ហៅរក, ពុះពោរឡើង, ដាលឡើង ។

**សមុទាចារ** ចុំ. [ សំ+ឧ+អា+ចរ+ណ, ចុរ៉ទ.អា. ] កិ.ប្រព្រឹត្តិឡើងព្រម, កិ.ពុះពោរ, កិ.ហៅរក, កិ.ដាលឡើង ។

**សមុស្សាហិតមានស** គុ. [ សមុស្សាហិត+មានស ] មានចិត្តគឺ...ឱ្យឧស្សាហ៍ព្រមហើយ, ...ឱ្យប្រឹងប្រែងព្រមហើយ ។

**សមុល្លបមាន** គុ. [ សំ+ឧ+លប+មាន ] កាលចរចា, កាលនិយាយឆ្លើយឆ្លង ។

**សមោធាន** នចុំ. [ សំ+អវ+ធា+យុ ] កិ.ប្រជុំ ។

**សមោធានេត្វា** អ. [ សំ+អវ+ធា+នា+ត្វា ] ប្រជុំហើយ ។

**សមោសរិត្វា** អ. [ សំ+អវ+សរ+ត.អា.+ត្វា ] ប្រជុំហើយ, ប្រជុំគ្នាហើយ

**សយតិ** កិ. [ សី+អ+តិ.វ. ] ដេក, រមែងដេក ។

**សយន** នចុំ. [ សី+យុ ] កិ.ដេក, ជាទីដេក, សម្រាប់ដេក ។ - **គត** គុ. ទៅហើយកាន់ទីជាទីដេក ។ - **ដ្ឋាន** ន. ទីជាទីដេក ។ - **ឃរសទិស** គុ. ប្រាកដស្មើដោយផ្ទះជាទីដេក ។ - **បិដ្ឋ** ន. បន្ទប់ជាទីដេក, ខាងក្រោយនៃទីជាទីដេក ។



**សយំ** និ. ខ្លួនឯង, ដោយខ្លួនឯង, ។ - **មតមច្ចក** ចុំ. ត្រីតូចដែលស្លាប់ខ្លួនឯង ។

**សរ** នចុំ. [ សរ+អ ] ស្រះ, ស្រះ, សំឡេង, ព្រួញ, សរ ។ - **តុណ្ឌ** ន. ចុងនៃព្រួញ, ចំពុះនៃព្រួញ ។ - **ទណ្ឌក** នចុំ. ដងនៃសរ ។ - **ភាណក** ន. កិ.ពោលដោយសំឡេង ។

**សរណ** នចុំ. [ សរ+យុ ] កិ.រលឹក, ជាទីរលឹក, ជាទីពឹង, ជាទីពុំនាក់ ។

**សរភញ្ញ** នចុំ. [ សរ+ភណ+ណ្យ ] កិ.ពោលដោយស្រះ, កិ.សូត្រដោយសំឡេង ។

**សរន្ត** គុ. [ សរ+អន្ត ] កាលរលឹក, កាលនឹកឃើញ ។

**សរាជិក** គុ. [ សហ+រាជ+ក+ត.រក. ] ប្រព្រឹត្តទៅព្រមនឹងដោយព្រះរាជា ។

**សរីរ** នចុំ. [ សរ+ឦរ ] សរីរៈ (រាងកាយ); វិ. **សរតិ គច្ឆតីតិ> សរីរំ** ។ - **និក្ខេប** ចុំ. កិ.ដាក់ចុះនូវសរីរៈ, កិ.ដាក់នូវសរីរៈ ។ - **បដិជគ្គន** នចុំ. កិ.ជប្រះនូវសរីរៈ, កិ.ថែទាំនូវ... ។ - **ប្បភា** ឥ. រស្មីនៃសរីរៈ, ពន្លឺនៃ... ។ - **និប្ផត្តិ** ឥ. កិ.សម្រេចនៃសរីរៈ ។ - **វលញ្ជ** នចុំ. វលញ្ជៈ (លាមក) ក្នុងសរីរៈ ។ - **សណ្ឋាន** នចុំ. សណ្ឋាននៃសរីរៈ, ទ្រង់ទ្រាយនៃ... ។

**សល្លក្ខេថ** កិ. [ សំ+លក្ខ+អ+ថ.ប. ] ចូរកំណត់ព្រម, ចូរកំណត់ ។

**សល្លកី** ឥ. ដើមរំពៅព្រៃ ។

សល្លបេន្ទ គុ. ( សំ+លប+ឯ+អន្ទ ) ការពោលគ្នា, ការនិយាយឆ្លើយឆ្លង ។

សល្លហុក គុ. [ សំ+លហុ+ក, ហ>ល, អស៊ំយោគ>ទ ] ស្រាល, ស្រាលព្រម ។ - វុត្តិ ន. អ្នកមានកិ.ប្រព្រឹត្តិស្រាល ។ - សរីរ គុ. អ្នកមានសរីរៈស្រាល ។

សល្លេសត្ថន នពុ. [ សល្ល+សត្ថន ] (ផ្ន) ជាបឹងកោសក៏តែសទ្ធសារ, ...ជាមិញមិញទ្រសារ ។

សវណកហេតុ ៥. [ សវណក+ហេតុ ] ហេតុ (ការ) ដែលគួរឲ្យដោយស្ដាប់ ។

សវន នពុ. [ សុ+យុ ] កិ.ស្តាប់, កិ.ឮ, ជាទីស្តាប់, ជាទីឮ ។

ស្វាក្ខាត គុ. [ សុ+អា+ខា+ត ] ដែល...ពោលហើយដោយប្រពៃ ។ - សាសនា ន. សាសនាដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ។

សវិតក្ក គុ. [ សហ+វិតក្ក ] ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ចង្អៀតចង្អល់ ។

សវិញ្ញាណកាវិញ្ញាណក គុ. ( សហ+វិញ្ញាណក+អវិញ្ញាណក ) ប្រព្រឹត្តទៅព្រមដោយទ្រព្យមានវិញ្ញាណនិងទ្រព្យមិនមានវិញ្ញាណ ។

សវិដ្ឋក ពុ. ផ្កាឈ្មោះសវិដ្ឋកៈ (ផ្កាកោក) ។

សស្ស នពុ. [ សស+ស ] សំទូង; វិ. សសន្តិ ជីវន្តិ ឯតេនាតិ> សស្សំ ។ - បរិបាកសម័យ ពុ. សម័យជាទីចាស់ទុំនៃ



សំទូង ។

សស្សត គុ. [ សស្ស+ត ] ទៀង, ទៀងទាត់, រឿយៗ វិ. សព្វទា សវន្តិ គច្ឆតីតិ> សស្សតោ ។

សសាវកសង្ឃ គុ. [ សហ+សាវកសង្ឃ ] ប្រព្រឹត្តទៅមួយអន្លើដោយសង្ឃជាសាវ័ក ។

សស្សាមិក គុ. [ សហ+សាមិក ] ប្រព្រឹត្តទៅមួយអន្លើដោយស្វាមី, ...ដោយប្ដី ។

សស្សុរ ពុ. [ សស+ឧរ ] ឪពុកក្មេកឬពុកក្មេក វិ. សសតីតិ> សស្សុរោ ។

សស្សូ ៥. [ សស+ឩ ] ម្ដាយក្មេក ។

សហ ន. ដូច សទ្ធឹ ។

សហត្ថា ន. [ សហ.ត្+អា ? , ន.វិ.>អា ] ដោយដៃនៃខ្លួន ។

សហន នពុ. [ សហ+យុ ] កិ.អត់ធន់, សេចក្ដីអត់ទ្រាំ ។

សហាយក ឬសហាយ ពុ. ( សហ+អយ+ណ ) អ្នកប្រព្រឹត្តទៅជាមួយគ្នាក្នុងកិច្ច (សំឡាញ់); វិ. សហ អយតិ គច្ឆតីតិ> សហាយកោ ។ ៥. សហាយិកា ។

សហាយតា ន. [ សហាយក+តា ] ភាពនៃ...ជាសំឡាញ់, សហាយតាគុណ ។

សហស្ស ព.សំ. ពាន់ (១.០០០) ។ - រង្សី ន. ឈ្មោះសហស្សរង្សីៈ

(ឈ្មោះព្រះឥន្ទ្រ) មានភ្នែកច្រើន, មានភ្នែកមួយពាន់ ។ - ធារ-ធនុ នពុ. ធ្នូប្រដាប់នូវកម្លាំងនៃបុរសមួយពាន់នាក់ ។ - ធីកា ន. ផង់ដីពេញដោយពាន់នៃ... ។ - កូដាគារបរិវារ គុ. មានផ្ទះប្រកបដោយកំពូលមួយពាន់ជាបរិវារ ។

**សហេសា** ក. ដោយរហ័ស, ដោយប្រញាប់ ។

**សហេសានុបវិត្ត** គុ. [ សហេសា+អនុបវិត្ត ] ដែលកែងតាមបៀតបៀន ដោយរហ័ស (ឆ្លងកែង) ។

**សហិត** គុ. [ សហ+ហិត ] (ពុទ្ធ.) ប្រព្រឹត្តទៅព្រមរមៀលដោយ ប្រយោជន៍ ។

**សា** ពុ. [ ... ] ដូច ... ឧ. សាមិកស្ស ចចនំ សុត្វា ... សា ។

**សា** សព្វ. ន. [ ត>ស+អិ.រី.>សា ] នោះ ។

**សាក** ពុ. [ សក+ណ ] របស់ដែលគេទំពារ (បន្លែបង្អែម); ឧ. សាយតិ មដិយតីតិ> សាកោ ។ សាកប្ប: ក៏បាន ។

**សាកច្ឆា** ន. [ សហ+កថ+ឆ, ថ>ឆ, ត>ឆ ] ក.សាកច្ឆា ឧ. សហ សម្មា ចា រធិរោចេន កថា> សាកច្ឆា ។

**សាកដិក** គុ. [ សកដ+ណិក ] អ្នកត្រាច់ទៅដោយរទេះ, អ្នកបររទេះ; ... រទេះ; ឧ. សកដេន ចរតីតិ> សាកដិកោ ។

**សាកិយ, សាក្យ** ន. សក្យ:, ជនសក្យ: ។



**សាកុណិក** គុ. [ សកុណ+ណិក ] អ្នកសម្លាប់នូវសត្វស្លាបហើយរស់ នៅ (ព្រានសត្វស្លាប); ឧ. សកុណេ ហន្ត្វា ជីវតីតិ> សាកុណិកោ ។

**សាកេតវាសី** គុ. [ សាកេត+វស+ណី ] អ្នកនៅក្នុងក្រុងសាកេត ។

**សាខា** ន. [ សាខ+អ+អា.ន. ] មែក, មែកឈើ ។ - ភង្គ ន. វត្ថុ ដែលគេបញ្ជីកាត់ពីមែកឈើ, មែកឈើកាត់ ។ - វិដប-បលាស នពុ. មែកនិងប្រគាបនិងស្លឹក ។

**សាខានុសាខា** ន. [ សាខា+អនុសាខា ] មែកតូចនិងមែកធំ, មែកនិង មែកជាហើយដាច់ ។

**សាដកយុគ** នពុ. [ សាដក+យុគ ] គូនៃសាដក ។

**សាដ្ឋកថ** គុ. [ សហ+អដ្ឋកថា ] ប្រព្រឹត្តទៅព្រមដោយអដ្ឋកថា ។

**សាណ** នពុ. [ សណ+ណ ] ធ្មៃ, សំពត់ធ្មៃ, សំពត់ដែលគេធ្វើដោយធ្មៃ ។

**សាណិ** ន. របាំង, វាំងនន ។ - កណ្ណ ពុ. ជាយនៃរាំង, មុខនៃ... ។ - បាការ ពុ. កំពែងគឺរបាំង ។

**សាតច្ច** នពុ. [ សតត+ណ្យ ] ភាពនៃសេចក្ដីព្យាយាមប្រព្រឹត្តទៅ រឿយៗ, ក.ប្រព្រឹត្តទៅរឿយៗ; ឧ. សតតស្ស ភាវោ> សាតច្ចំ, សតតំ ឯវ វា> សាតច្ចំ ។ - កិរិយាវស ពុ. អំណាចនៃកិ.ធ្វើនូវសេចក្ដីព្យាយាមប្រព្រឹត្តទៅរឿយៗ ។

**សាតតិក** គុ. [ សតត+ណិក ] មានព្យាយាមប្រព្រឹត្តទៅរឿយៗ ។

**សាតសិត** គុ. [ សាត+សិត ] អាស្រ័យរឿងសេចក្ដីត្រេកអរ, (សាត< សទ+អ, ទ>ត, ស>សា = បា. សាតិយតិ អស្សាទិយតីតិ> សាតំ ។

**សាឋេយ្យ** នាំ. [ សឋ+ណេយ្យ ] ភាវៈនៃបុគ្គលអ្នកអួតអាង ។

**សាទាន** គុ. [ សហ+អាទាន ] ប្រព្រឹត្តទៅព្រមអន្លើដោយសេចក្ដីប្រកាន់មាំ, ប្រកបដោយសេចក្ដីប្រកាន់ ។

**សាទិយតិ** ក. [ សាទ+ឥ.ក.+យ+អតិ.វ. ] ត្រេកអរ ។

**សាធយតិ** ក. [ សាធ+ណយ+តិ.វ ] ឲ្យសម្រេច, ធ្វើឲ្យសម្រេច ។

**សាធារណ** នាំ. [ សហ+អា+ធរ+យុ, សហ>សា ] ទូទៅ, សាធារណៈ, សាធារណ៍; (បា. សមំ សាធារយន្តិ គសិទ្ធិ> សាធារណំ) ។

**សាធុ** នាំ. [ សាធ+ឧ ] (ការ) ញ៉ាំងប្រយោជន៍ឲ្យសម្រេច; បា. អត្តំ សាធេតីតិ> សាធុ ។ គុ. ប្រពៃហើយ, ស្រួលហើយ, ល្អហើយ ។ ប្រើជា សាធុ៎, សាធុ៎ ក៏បាន ។ -ការ គុ. សំឡេងជាគ្រឿងធ្វើជា សាធុ, កិ.ធ្វើសំឡេងថាសាធុ ។ -រស គុ. រសល្អ, រសឆ្ងាញ់ ។ -រូប គុ. មានសភាពល្អ, មានសភាពញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ -វិហារី គុ. អ្នកនៅដោយការញ៉ាំងប្រយោជន៍ឲ្យសម្រេច, ពេលនិ.នៅស្រួលជាប្រក្រតី ។



**សាធេយ្យ** ក. [ សាធ+ណេ+ឯយ្យ.ស. ] គប្បីឲ្យសម្រេច ។

**សានិ** គុ. [ ស+អេកា.វិ.>សានិ ] របស់ខ្លួន, ជារបស់ខ្លួន (អត្ត>ស) ។

**សានុចរ** គុ. [ សហ+អនុចរ ] ប្រព្រឹត្តទៅព្រមអន្លើដោយបុរសអ្នកត្រាច់ទៅតាម, ប្រព្រឹត្តទៅមួយអន្លើដោយ ទន្និភគៈដូចជាបុរសអ្នកដើរតាម ។

**សាបតេយ្យ** នាំ. [ ស+បតិ+ណេយ្យ ] ទ្រព្យជាប្រយោជន៍ដល់ជនជាម្ចាស់នៃទ្រព្យ (ទ្រព្យ, សម្បត្តិ); បា. សស្ស ធនស្ស បតិ> សបតិ, សបតិនោ ហិតំ> សាបតេយ្យំ ។

**សាប, សាបថ** គុ. [ សប+ណ ] សម្បថ, សេចក្ដីសម្បថ, ពាក្យសម្បថ ។

**សាមគ្គី** ឥ. [ សមគ្គ+ណី ] ភាវៈនៃសេចក្ដីព្រមព្រៀង; បា. សមេ គច្ឆតិ បវត្តតីតិ> សមគ្គោ, សមគ្គស្ស ភាវោ> សាមគ្គី ។ គុណនាមក៏បាន ។

**សាមញ្ញ** នាំ. [ សមណ+ណ្យ ] ភាវៈនៃសមណៈ, ភាវៈនៃបុគ្គលអ្នកស្ងប់, សាមញ្ញគុណ, ធម្មតា; បា. សមណស្ស ភាវោ> សាមញ្ញំ ។ មួយទៀត សមាន+ណ្យ = បា. សមានំ ឯវ> សាមញ្ញំ ។

**សាមញ្ញតា** ឥ. [ សាមញ្ញ+តា ] សេចក្ដីប្រតិបត្តិជាប្រយោជន៍ដល់សមណៈ; បា. សមណានំ ហិតា (បដិបត្តិ)> សាមញ្ញា, សាមញ្ញា ឯវ> សាមញ្ញតា ។

**សាមន្ត, -តា** គុ. [ សំ+អន្ត, និគ្គហិត>ម, ស>សា ] ជុំវិញ, ជិតខាង ។ **-រាជា** ន. ព្រះរាជាជិតខាង ។

**សាមណេរ** ពុ. [ សមណ+ណេរ ] បព្វជិតជាកូនចៅនៃសមណៈ (សាមណេរ); វិ. **សមណស្ស អបច្ចំ> សាមណេរោ** ។ ឥ. ធុះព្ទ > សាមណេរី ។

**សាមំ** និ. ឯង, ខ្លួនឯង ។ ន. ឆ្នាំ (ដូច **សំវច្ឆរ**) ។

**សាមាកនីវារ** ពុ. [ សាមាក+នីវារ ] ស្រងែនិងស្កួយ ឬស្រងែនិងស្កៅ ។

**សាមាយិក** គុ. [ សមយ+ណិក ] ប្រព្រឹត្តទៅក្នុងសម័យ, កើតក្នុងសម័យ; វិ. **សមយេ ចក្កតិ> សាមាយិកោ (ករ-ណោ)** ។

**សាមាវតីបមុខ** គុ. [ សាមាវតី+បមុខ ] មានព្រះនាងសាមាវតីជាប្រមុខ, -ជាប្រធាន ។

**សាមិ** អា.ន. បពិត្រម្ចាស់, បពិត្រអ្នកជាម្ចាស់, បពិត្រស្វាមី ។

**សាមិក** ពុ. [ សំ+អាមិ+ក.ស. ] ម្ចាស់, ជនជាម្ចាស់, ស្វាមី, ប្ដី ។

**សាមីចិមគ្គ** គុ. [ សាមីចិ+មគ្គ ] (កម្ម ឬកិច្ច) ត្រឹមតែសេចក្ដីគោរពក្រែង ។

**សាយ, សាយំ** ន. ឬ និ. [ សា+យ ] (កាល) ជាទីញ៉ាំងថ្ងៃឱ្យអស់ (វេលាល្ងាច, ថ្ងៃល្ងាច, ថ្ងៃរសៀល); វិ. **សាយតិ ធនំ អេចសាយតិ ឯត្ថាតិ> សាយោ** ។ **-បាតំ** និ. ក្នុងវេលា



ល្ងាចនិងក្នុងវេលាព្រឹក, ទាំងល្ងាចទាំងព្រឹក ។

**សាយណ្ហ** ន. [ សាយំ+អណ្ហ ] កាលជាទីអស់ទៅនៃថ្ងៃ (វេលាល្ងាច, វេលារសៀល); វិ. **អហស្ស សាយោ> សាយណ្ហោ** ។ **-សម័យ** ពុ. សម័យជាទីអស់ទៅនៃថ្ងៃ, សម័យនៃថ្ងៃរសៀល ។

**សាយមាស** ន.ពុ. [ សាយំ+អស+អ ] ភោជនដែលបុគ្គលគប្បីបរិភោគក្នុងវេលាល្ងាច; វិ. **សាយំ អសិតព្វន្តិ> សាយមាសំ** ។

**សារគន្ធ** ពុ. [ សារ+គន្ធ ] ក្លិនខ្លឹម ។ **សារ**<សរ+ណ ។

**សារជីវិតតា** ឥ. [ សារជីវិត+តា ] ភាវៈនៃ...មានជីវិតជាខ្លឹម ។

**សារត្ត** គុ. [ សរ្ត+អញ្ច+ត ] ត្រេកអរខ្លាំង, ដែលត្រេកអរខ្លាំង ។ **-វត្ត** គុ. អ្នកត្រេកអរដោយសេចក្ដីត្រេកអរខ្លាំង (អ្នកត្រេកអរខ្លាំងក្រៃលែង) ។

**សារថិ** ពុ. [ សារ+ថិ, ស>សា ] ជនអ្នកទៅព្រមដោយរថ (អ្នកបររថ); វិ. **រថេន សហ សរតិ គច្ឆតីតិ> សារថិ** ។ **សារេតីតិ វា> សារថិ** ។

**សារទិក** គុ. [ សារទ+ណិក ] ដែលកើតក្នុងសរទកាល (កាលជាទីត្រេកអរនៃកុមុទ); **សរទកាលេ និព្វត្តំ> សារទិកំ** ។

**សារទិដ្ឋិ** គុ. [ សារ+ទិដ្ឋិ ] អ្នកមានសេចក្ដីយល់ឃើញជាធម៌មានខ្លឹម ។

**សាររតិ** គុ. [ សារ+រតិ ] អ្នកមានសេចក្ដីចូលចិត្តជាធម៌មានខ្លឹម ។

**សារម្ភ** គុ. [ សហ+អារម្ភ ] វាចៈប្រព្រឹត្តទៅព្រមដោយអន្ទើដោយសេចក្តីប្រណាំងប្រជែង; វិ. សហ អារម្ភេន ចត្ថតីតិ> សារម្ភោ ។

**សារាណីយ** គុ. [ សរ+អនីយ, ឧ>ណ ] គឺ...គប្បីរលឹក; វិ. សរិ. តព្វន្តិ> សារាណីយំ ។

**សារេត្វា** អ. [ សរ+ណេ+ត្វា ] ឱ្យរលឹកហើយ, រំលឹកហើយ ។

**សាលមហ** ពុ. [ សាលក+មហ ] គឺ.ឆ្លងនូវសាលា, គឺ.បូជានូវសាលា ។

**សាលវន** នបុ. [ សាល+វន ] សាលវ័ន, ព្រៃដែលដេរដាសដោយសាលព្រឹក្ស, ព្រៃនៃសាលព្រឹក្ស ។

**សាលិកពោតក** ពុ. [ សាលិក+ពោតក ] កូនរបស់សត្វសាលិកា ។

**សាលិ** ពុ. ស្រូវសាលី ។ -**ក្ខេត្តបាលិកា** ឥ. អ្នករក្សានូវស្រែនៃស្រូវសាលី ។ -**គព្ភ** ពុ. គភ៌នៃស្រូវសាលី ។ -**តណ្ឌុលបុរ** គុ. ដ៏ពេញដោយអង្ករនៃស្រូវសាលី ។ -[illegible]**ភោជនសុខសមិត** គុ. ប្រាកដស្មើដោយសុខដែលកើតអំពីកិ.បរិភោគនូវបាយសាលីនិងសាច់ ។ -**សីស** នបុ. ក្បាលនៃស្រូវសាលី ។

**សាវក** ពុ. [ សុ+ណ្វុ ] អ្នកស្តាប់, សាវ័ក; វិ. សុណាតីតិ> សាវកោ ។ -**ត្ត** នបុ. ភាវៈនៃ...ជាសាវក ។ -**យុគ** នបុ. គូនៃសាវ័ក ។ ឥ. **សាវិកា** ។

**សាវជ្ជ** គុ. [ សហ+អវជ្ជ ] ប្រព្រឹត្តទៅព្រមដោយទោស, -ដោយ



ទោសដែលបុគ្គលគប្បីវៀរ; វិ. សហ អវជ្ជេន ចត្ថតីតិ> សាវជ្ជោ ។ អ. អាគម ។

**សាវិត** គុ. [ សុ+ណេ+ត ] គឺ...ឱ្យឮហើយ ។

**សាវេតុំ** អ. [ សុ+ណេ+តុំ ] ដើម្បីឱ្យឮ, ដើម្បីញុំាង...ឱ្យឮ ។

**សាសន, -នា** នបុ. ឬ ឥ. [ សាស+យុ ] ពាក្យជាគ្រឿងប្រៀនប្រដៅ (ពាក្យបណ្តាំ, សំបុត្រ, សាសនា); វិ. សាសតិ ឯតេនាតិ> សាសនំ ។

**សាសប** ពុ. [ សាស+អប ] គ្រាប់ស្ពៃ ។ -**ពីជ** នបុ. ពូជនៃគ្រាប់ស្ពៃ ។

**សាហុ** ន. ឬ និ. [ សាធ+ឧ, ធ>ហ ] ពាក្យប្រែដូចសាធុ ។

**សាហស** ន. [ សហ+ណ, គុណស ] រហ័ស, អំពើរំលោភ, ប្រញាប់ប្រញាល់, កំហែង ។

**សាហសិក** គុ. [ សាហស+ណិក ] ប្រព្រឹត្តទៅដោយរហ័ស, (ទាន់ហន់) ។

**សិក្កា** ឥ. [ សក+អ+អា.ឥ., ក>ក្ក, អនៃស>ឥ ] សង្រែក ។

**សិក្ខតិ** គិ. [ សិក្ខ+អ+តិ_វ. ] សិក្សា, រៀន ។

**សិក្ខា** [ សិក្ខ+អ+អា.ឥ. ] ធម្មជាតិដែលបុគ្គលគប្បីសិក្សា, -គប្បីរៀន (ការសិក្សា); វិ. សិក្ខិតព្វាតិ> សិក្ខា ។

**សិក្ខាបេតិ** គុ. [ សិក្ខ+ណាបេ+តិ_វ. ] ឱ្យសិក្សា, ញុំាង...ឱ្យរៀន ។

**សិក្ខិតវត្ត** គុ. [សិក្ខិត+វត្ត] អ្នកដែលសិក្សាហើយ ។

**សិខរ** នាម. [សិ+ខរ] កំពូល ។ _ **ចូឡិហោ** ន. ចុងនៃកំពូលទាំងឡាយ ។

**សិខី** ពុំ. [សិខា+ឦ] ក្ងោក, ភ្លើង បា. **សិខា អស្ស អត្ថីតិ> សិខី** ។

**សិង្គធនុ** នាម. [សិង្គ+ធនុ] ធ្នូដែលបុគ្គលធ្វើដោយស្នែង, ដោយភ្លុក ។

**សិង្ឃាណ** ឬ **សិង្ឃាណិ** ពុំ. ធកក ឬទឹកធកក ។

**សិង្គិលសកុណ** ពុំ. [សិង្គិល+សកុណ] សត្វស្លាបត្រចេះ ត្រចោង, សត្វត្រចេះត្រចោង ។

**សិញ្ច** គិ. [សិច+អ+ញ..., ...] ដួសស្រោច, ដួសបាច, ដួសស្តារ ។

**សិត** គុ. [សស+ត...+ត, ...] ញញឹម, កិ.ញញឹម ។ _ **ការណ** នាម. ហេតុនៃកិ.ញញឹម ។ _ **បាតុកម្ម** នាម. ធ្វើនូវកិ.ញញឹមឱ្យប្រាកដ, ធ្វើឱ្យប្រាកដនូវកិ.ញញឹម ។ សិតិ<សិ+ត = អាស្រ័យហើយ ។

**សិតា** ន. រាក់ពំណាំទាំងឡាយ ។

**សិត្ត** គុ. [សិច+ត] ដី...ស្តារហើយ,. បាចហើយ ។

**សិត្តគណនា** ន. [សិត្ត+គណនា] កិ.រាប់នូវគ្រាប់ ។

**សិថិល** គុ. ធូរ, នឹងធូរ ។ _ **ករណ** ពុំ. កិ.ចាប់ដឹងធូរ, កិ.កាន់យកដឹងធូរ ។



**សិន្ធវ** ពុំ. [សិន្ធុ+ណ] សេះ, សេះសិន្ធវៈ; សេះកើតក្នុងជនបទឈ្មោះសិន្ធុ បា. **សិន្ធូសុ អជានិយោ ជនបទោ> សិន្ធុ, តត្រ ភវោ> សិន្ធវោ** ។ _ **កុល** នាម. ត្រកូលនៃសេះសិន្ធវៈ ។ _ **រដ្ឋ** នាម. ដែនឈ្មោះសិន្ធុ ។

**សិនិទ្ធ** គុ. [សិនិហ+ត, ហ>ធ] ស្និទ្ធ, ស្និទ្ធជិត, ឆ្លាញ់ ។ _ **ឃាតុ** ន. បាយដីស្និទ្ធ, បាយគ្រឿង ។

**សិនេរុ** ស.ន. ភ្នំឈ្មោះសិនេរុ ។ _ **បាទ** ពុំ. ជើងនៃភ្នំឈ្មោះសិនេរុ ។ _ **មត្ថក** ន. កំពូលនៃភ្នំសិនេរុ ។

**សិនេហ** ពុំ. [សិនិហ+ណ] សេចក្តីស្រឡាញ់, សេចក្តីស្នេហា; វិ. **សិនិយ្ហតីតិ> សិនេហោ** ។ _ **បុព្វក** គុ. មានសេចក្តីស្រឡាញ់ជាដែនកើតមុន ។ _ **មត្ត** គុ. គ្រាន់តែសេចក្តីស្នេហា ។ _ **សត្ត** ពុំ សត្វមានសេចក្តីស្រឡាញ់, ជាប់ដោយ... ។

**សិនេហិត** គុ. [សិនេហ+ឥ+ត] ប្រព្រឹត្តទៅដោយសេចក្តីស្នេហា, ដល់ហើយនូវសេចក្តីស្នេហា ។

**សិប្ប** នាម. [សិ+ប្ប] សិប្បៈ ឬសិល្បៈ បា. **អត្តនោ ហិត- មិច្ចន្តេហិ សេវិយតេតិ> សិប្បំ** ។ _ **ទស្សន** នាម. កិ. សម្តែងនូវសិល្បៈ ។

**សិប្បិយ** គុ. [សិប្ប+ឥយ] អ្នកមានសិល្បៈ; វិ. **សិប្បំ យស្ស អត្ថីតិ> សិប្បិយោ** ។

**សិប្បូបជីវន** នាម. [សិប្ប+ឧបជីវន] ជីវិកា, វុត្តិដែលគាសដោយដើម

រកា ។

**សិយា** គ. [ អស+អ+ឯវច.ស. ] គប្បីមាន, គប្បីជា.... ។

**សិយុំ** គ. [ អស+អ+ឯវច.ស. ] គប្បីមាន, គប្បីជា... ។

**សិរី** ឥ. [ សិ+រ+ឦ ] សិរី (វិ. **កតបុញ្ញេហិ សេវិយតេតិ> សិរី** ។ -**វិភវ** ចុំ. សម្បត្តិប្រកបដោយសិរី, ភោគៈគឺបុគ្គលគប្បីសោយព្រកបដោយ... ។ -**សយន** នចុំ. ទីជាទីដេកប្រកបដោយសិរី ។ -**សោភគ្គ** គុ. មានចំណែកដ៏ល្អប្រកបដោយសិរី, ដ៏លើសដោយលំអនៃសិរី, មានលំអនៃសិរីដ៏ប្រសើរ (សោភគ្គ <សោភន+អគ្គ) ។

**សិរីគព្ភ** ចុំ. [ សិរី+គព្ភ ] បន្ទប់ឬល្វែងប្រកបដោយសិរី ។

**សិលា** ឥ. [ សិល+អ+អា.ឥ. ឬសិ+លេ ] ថ្ម (វិ. **សេត្តេហិ សេវិយ.តីតិ > សិលា**) ។ -**ថម្ភ** ចុំ. សសរថ្ម, សសរជាវិការៈនៃថ្ម ។

**សិលិដ្ឋក** គុ. [ សិលិស+ត+ក ] ស្រឡះស្រឡៀ, ត្រួយ ។

**សិលុច្ចយ** ចុំ. [ សិលា+ឧច្ចយ ] ប្រទេសជាទីសន្សំនូវថ្ម, ភ្នំ ។

**សិវិកា** ឥ. [ សិ+ណ្វុ, ឥុ.វ.ព., អនៃវ>ឥ ] វ, អង្រឹងស្នែង, គ្រែស្នែង (វិ. **សុខត្ថិកេហិ សេវិយតេតិ> សិវិកា**) ។

**សីឃ** គុ. [ សី+ឃ ] ឆាប់, រហ័ស, លឿន, រួសរាន់ ។

**សីឃស្ស** ចុំ. [ សីឃ+អស្ស ] សេះលឿន ។

**សីឃជវស្ស** ចុំ. [ សីឃ+ជវ+អស្ស ] សេះពេញលក្ខណៈដ៏រហ័ស, សេះ



មានល្បឿនដ៏រហ័ស ។

**សីត** គុ. [ សី+ត ] ត្រជាក់, រងា ។ -**កាល** ចុំ. កាលនៃរដូវត្រជាក់ ។ -**បីឡិត** គុ. គឺត្រជាក់បៀតបៀនហើយ ។ -**វាតបរិត្តាណ** ចុំ. ជាគ្រឿងការពារត្រជាក់និងខ្យល់ ។

**សីតល** គុ. [ សីត+លា+អ ] ត្រជាក់, (វិ. **សីតំ គុណំ លាតីតិ> សីតលំ**) ។

**សីតុណ្ហាទិវស** ន. [ សីតុណ្ហាទិ+វស ] អំណាចនៃបច្ច័យមានត្រជាក់និងក្តៅជាដើម ។

**សីតូទក** នចុំ. [ សីត+ឧទក ] ទឹកត្រជាក់ ។

**សីល** នចុំ. [ សិ+លេ ឬសីល+អ ] សីល, ប្រក្រតី (វិ. **សិនោតិ ពន្ធតិ ចិត្តមេតេនាតិ> សីលំ**) ។ -**គន្ធ** ចុំ. ក្លិននៃសីល ។ -**តេជ** ចុំ. តេជៈនៃសីល ។ -**ព្វតបត្ត** គុ. រកការត្រឹមតែសីលនិងវត្ត ។ -**ភេទ** ចុំ. កិ.បែកនៃសីល, កិ.ធ្លាយនៃសីល ។ -**រក្ខិត** គុ. អ្នករក្សានូវសីល ។ -**សម្បន្ន** គុ. ដល់ព្រមហើយដោយសីល, បរិបូណ៌ដោយសីល ។

**សីលវន្ត** គុ. [ សីល+វន្តុ ] អ្នកមានសីល; វិ. **សីលំ យេសមត្ថីតិ> សីលវន្តោ** ។

**សីលវា** គុ. [ សីល+វន្តុ ] អ្នកមានសីល; វិ. **សីលំ យស្ស អត្ថីតិ> សីលវា** ។

**សីលវតំ** គុ. [ សីលវន្តុ+នំ.វិ., ន្តុ+នំ>តំ ] នៃបុគ្គលអ្នកមានសីលទាំង

ឡាយ ។

**សីលាចារាជ្ជវមទ្ទវាទិគុណសម្បន្នសមុទិត** គុ. [សីល+អាចារ+អាជ្ជវ+មទ្ទវ+អាទិ+គុណសម្បន្ន+សមុទិត] អ្នកមានគុណសម្បត្តិបានសីលនិងអាចារៈ និងភាវៈនៃអ្នកស្មោះត្រង់ និងភាវៈនៃអ្នកទន់ភ្លន់ជាដើមឲ្យកើតឡើងហើយ, ឲ្យតាំងឡើងហើយ ។

**សីស** ន.ប៉ុ. ឬ ប៉ុ. [សិរ ឬ សី+ស] សីសៈ, ក្បាល; បា. សិនាតិ ពន្ធតិ កេសេ ហោតិ ករណាទិសេន ឯត្ថាតិ> សីសំ, សយន្តិ ឯត្ថ ឩកាយោតិ> សីសំ ។ - វេទនា ន. គឺ.ចុកក្បាល ។ - ហត្ថអាទិ គុ. កិច្ចមានគឺ.ពាក់ខ្លួនក្បាលជាដើម ។ - ចុណ្ណនាទិបត្ត គុ. ពោត្រូវបែកគឺ.បើកនៃក្បាលជាដើម, គឺ.ត្រូវចោលនៃក្បាលជាដើម ។ - រោគាទិភេទ ប៉ុ. ផ្សេងដោយរោគមានរោគក្នុងក្បាលជាដើម ។ - វេឋន ឬ វេដ្ឋន ន.ប៉ុ. សំពត់សម្រាប់រុំក្បាល, ឈ្នួតនៃសីសៈ ។

**សីហ** ប៉ុ. [សហ្សុ+សូហ] សត្វដែលមានមាឌល្អប្រពៃ (សីហៈ); វ. ហិនតិ ហិំសតីតិ> សីហោ ។ - នាទ ប៉ុ. គឺ. សម្រែកនៃសត្វសីហៈ, សម្រែកជាគឺ.សម្រែកនៃសីហៈ, សីហនាទ ។ - បញ្ជរ ន.ប៉ុ. សីហបញ្ជរ, ភាពនៃសត្វសីហៈ, បង្អួចមានលម្អដូចជាភាពនៃសត្វសីហៈ, គឺ.ដេកនៃសីហៈ ។

**សុអញ្ជនអក្ខិ** ន.ប៉ុ. [សុ+អញ្ជន+អក្ខិ] ភ្នែកដែលបន្តក់ល្អហើយ, ដែលបន្តក់ដោយល្អ ។



**សុកត** គុ. [សុ+ករ+ត] ដែល...ធ្វើល្អហើយ; វ. សុដ្ឋុ ករីយតិ> សុកតោ ។ - កម្មវិនាសនលក្ខណ គុ. មានគឺ.ញ៉ាំងអំពើដែលបុគ្គលធ្វើល្អហើយឲ្យវិនាសជាលក្ខណៈ ។

**សុករ** គុ. [សុ+ករ+អ] គឺបុគ្គលធ្វើបានដោយងាយ, ដែលងាយធ្វើ; វ. សុខេន ករីយតេតិ> សុករំ ។

**សុក្ក** គុ. [សុច+រ, ច>ក>ក្ក] ស, ពណ៌ស ។

**សុក្កំស** ប៉ុ. [សុក្ក+អំស] ចំណែកនៃធម៌ស ។

**សុកថិត** គុ. [សុ+កថ+ឥ.អា.+ត] គឺ...ពោលល្អហើយ ។

**សុក្ខ** គុ. [សុស+ត, ត>ខ, សុស្ស] ស្ងួត, ក្រៀម ។ - កដ្ឋខណ្ឌក ន.ប៉ុ. កំណាត់នៃឈើស្ងួត ។ - ទារុ ន.ប៉ុ. ឈើស្ងួត, ឧសស្ងួត ។

**សុក្ខាបេតិ** គុ. [សុស្ស+ណាបេ+ឥ ...] ឲ្យស្ងួតហើយ ។

**សុខ** ន.ប៉ុ. [សុ+ខន ...] សុខ, ស្រួល, ងាយ បា. សុដ្ឋុ ខនតីតិ> សុខំ, សុខេន ខមិយតីតិ> សុខំ ។ - កាមី គុ. អ្នកប្រាថ្នានូវសេចក្ដីសុខ ។ - ប្បត្ត គុ. អ្នកដល់ហើយនូវសេចក្ដីសុខ ។ - បរិយេសី គុ. អ្នកស្វែងរកនូវសុខ ។ - ភាគិក មានរូបជាសុខ, មានរូបនាំមកនូវសុខ ។ - សម្ពាស គុ. មានគឺ.ពោលនាំមកនូវសេចក្ដីសុខ, មានសេចក្ដីសប្បាយនាំមកនូវសេចក្ដីសុខ ។ - សេយ្យ ន. គឺ.ដេកជាសុខ, គឺ.ដេកនាំមកនូវសុខ ។

**សុខានុភវនដ្ឋាន** នថុំ. [ សុខ+អនុភវន+ឋាន ] ទីជាទីសោយនូវសេចក្ដីសុខ, ទីជាទីទទួលនូវ... ។

**សុខាវហ** គុ. [ សុខ+អាវហ ] នាំមកនូវ..., ជាទីនាំមកនូវ... ។

**សុខិត** គុ. [ សុខ+ឥ+ត ] ដល់ហើយនូវសេចក្ដីសុខ, ប្រព្រឹត្តទៅហើយដោយសេចក្ដីសុខ; វិ. **សុខំ សុខេន វា ឥតោ បត្តោតិ> សុខិតោ** ។

**សុខុទ្រយ** គុ. [ សុខ+ឧទ្រយ ] មានសុខជាកំរៃ, ចម្រើនដោយសុខ, ជាទីញ៉ាំងសុខឱ្យចម្រើន ។

**សុខុម** គុ. [ សុខ+ឧម ] សុខុម, ល្អិត, ឆ្មារ ។ - **វត្ថនិវត្ថ** គុ. ស្លៀកហើយនូវសំពត់មានសាច់ល្អិត ។

**សុខេត្ត** នថុំ. [ សុ+ខេត្ត ] ស្រែដ៏ល្អ ។

**សុខេសី** គុ. [ សុខ+ឥស+ណី ] អ្នកស្វែងរកនូវសេចក្ដីសុខ; វិ. **សុខំ ឯសតីតិ> សុខេសី** ។

**សុគត** គុ. [ សុ+គម+ត ] ទៅដោយល្អ, ព្រះសុគត ។ - **ប្បសត្ថ** គុ. ដែលព្រះសុគតសរសើរហើយ ។ - **មហាបំសុកូលចីវរ** នថុំ. មហាបង្សុកូលចីវររបស់ព្រះសុគត ។

**សុគន្ធ** គុ. [ សុ+គន្ធ ] មានក្លិនល្អ, មានក្លិនក្រអូប ។

**សុគតិ** ឥ. [ សុ+គតិ ] ដំណើរល្អ, កិ.ទៅដោយល្អ ( គតិ<គម+តិ = វិ. **គមនំ> គតិ, សោភណា សុដ្ឋុ វា គតិ> សុគតិ**) ។



- **សំវត្តនិក** គុ. ប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីសុគតិ, ប្រកបក្នុងកិ.ញ៉ាំងសត្វឱ្យប្រព្រឹត្តទៅព្រមដើម្បីសុគតិ ។

**សុគហិត** គុ. [ សុ+គហ+ឥ.អា.+ត ] ដែលខ្លួនកាន់យកល្អហើយ,... ។

**សុគោបិត** គុ. [ សុ+គុប+ឥ.អា.+ត ] ដែលខ្លួនគ្រប់គ្រងល្អហើយ ។

**សុង្ក** ថុំ. [ សុង្ក+អ ] ស្ងួយ, អាករ វិ. **សុង្កតិ យេន សោ> សុង្កោ** ។

**សុចិ** ឥ. [ សុច+ឥ ] សេចក្ដីស្អាត, របស់ស្អាត ។ - **កម្ម** គុ. អ្នកមានការងារដ៏ស្អាត ។ - **គវេសី** គុ. អ្នកស្វែងរកនូវសេចក្ដីស្អាត ។ - **គន្ធ** មានក្លិនក្រអូប ។ - **មំសូបសេចន** ន. ដែលលាយដោយសាកដ៏ស្អាត ។

**សុចិណ្ណ** គុ. [ សុ+ចរ+ត ត>ណ្ណ, លុប រ ] គឺ...ប្រព្រឹត្តល្អហើយ ។ <សុ+ចិ+ត — គឺ...សន្សំល្អហើយ ។

**សុឆន្ន** គុ. [ សុ+ឆទ+ត, ត>ន្ន, លុប ទ ] ដែលបុគ្គលបិទបាំងល្អហើយ, ប្រក់ល្អហើយ ។

**សុជម្បតិ** ន.ប. ទេវរាជឈ្មោះសុជម្បតិ (ព្រោះព្រះឥន្ទជាប្ដីនៃនាងសុជា ឬសុជាតា) ។

**សុជាត** គុ. [ សុ+ជន>ជា+ត ] កើតល្អហើយ ។

**សុជីវ** ថុំ. [ សុ+ជីវ ] រស់នៅដោយងាយ, កិ.រស់នៅដោយស្រួល ។

**សុញ្ញ** គុ. [ សុន+អ, ន+យ>ញ>ញ្ញ ] សូន្យ, ស្ងាត់, ទទេ វិ. **សុនតិ**

កុច្ឆភាទំ គច្ឆតិ> សុញ្ញំ ។

**សុញ្ញាគារ** នាម. [ សុញ្ញ+អគារ ] ផ្ទះដ៏ស្ងាត់ ។

**សុដ្ឋុ** និ. ដោយល្អ, ដោយស្រួល, ដោយប្រពៃ ។ - **តរ** គុ. ល្អជាង, ស្រួលជាង, ល្អដោយវិសេស ។ - **សមាហិត** គុ. មានចិត្តតាំងមាំហើយដោយល្អ ។

**សុណាតិ** កិ. [ សុ+ណា+តិ.វ. ] ស្តាប់, ឮ ។

**សុណាបិត** កិ. [ សុ+ណាបេ+ត ] គឺ...ឱ្យស្តាប់ហើយ, -ឱ្យឮហើយ ។

**សុណិសា ឬ សុណ្ហា** ឥ. [ សុ+ណិស+អា.ឥ. ] កូនប្រសាស្រី; វិ. សុណ្ហាគច្ឆតិ> សុណិសា ។

**សុត** កិ. ឬ គុ. [ សុ+ត ] គឺ...ឮហើយ, -ស្តាប់ហើយ; វិ. សុយ្យតេតិ> សុតោ ។ ន. កិ.ឮ, កិ.ស្តាប់ ។ - **កិច្ច** ន. កិច្ចគឺកិ. ស្តាប់, កិច្ចដោយពាក្យដែលខ្លួនស្តាប់ហើយ ។ - **គន្ធធារណ-គន្ធបដិបត្តិគន្ធ** ទ្វ. គន្ធគឺកិ.ស្តាប់ និងគន្ធគឺកិ.ទ្រទ្រង់ទុក និងគន្ធគឺសេចក្តីប្រតិបត្តិ, គន្ធគឺពុទ្ធវចនៈដែលខ្លួនស្តាប់ហើយ និងគន្ធគឺកិ.ទ្រទ្រង់ និងគន្ធគឺសេចក្តីប្រតិបត្តិ ។ - **បុព្វ** គុ. ដែល...ធ្លាប់ស្តាប់ហើយ ។

**សុត្ត** កិ. ឬ គុ. [ សុប ឬ សូច+ត ] ដែលដេកលក់ហើយ, ដោតក្រងហើយ ។ - **ប្បពុទ្ធោវិយ** ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។ - **ប្បវត្តិ** ន. ភាវៈនៃខ្លួនជាអ្នកដេកលក់ហើយព្រអេចហើយ ។ - **វត្ថកោសេយ្យវត្ថ** គុ. ដ៏ពេញដោយសំពត់



អំបោះ និងសំពត់សូត្រ; ដ៏ពេញដោយសំពត់គឺបុគ្គលធ្វើដោយអំបោះ និងសំពត់គឺបុគ្គលធ្វើដោយសូត្រ ។

**សុត្វា** អ. [ សុ+ត្វា ] ឮហើយ, ស្តាប់ហើយ ។

**សុទំ** និ. ឮថា, បានឮថា (ដូចកិរ,ខលុ) ។

**សុទឌ្ឍ** គុ. [ សុ+ទហ+ត ] ដែលភ្លើងឆេះល្អ, -ឆេះសុសហើយ ។

**សុទន្ត** គុ. [ សុ+ទម+ត ] ទូន្មានល្អហើយ, បង្ហាត់ល្អហើយ ។

**សុទស្ស** គុ. [ សុ+ទិស+អ ] គឺបុគ្គលឃើញបានដោយងាយ ។

**សុទិដ្ឋ** គុ. [ សុ+ទិស+ត ] គឺបុគ្គលឃើញល្អហើយ, -សម្តែងល្អហើយ ។

**សុទិន្ន** គុ. [ សុ+ទា+ត ] ដែល...ឱ្យល្អហើយ ។ - **ទាន** នាម. ទានដែលបុគ្គលឱ្យល្អហើយ ។

**សុទុត្តរ** គុ. [ សុ+ទុ+តរ+អ ] ដែលបុគ្គលឆ្លងបានដោយលំបាកក្រៃលែង ។

**សុទុទ្ទស** គុ. [ សុ+ទុ+ទិស+អ ] ដែលបុគ្គលឃើញបានដោយលំបាកក្រៃលែង ។

**សុទេសិត** កិ. [ សុ+ទិស+ឥ.អា.+ត ] ដែល...សម្តែងល្អហើយ, -សម្តែងហើយដោយល្អ ។

**សុទ្ធ** គុ. [ សុធ+ត ] ស្អាត, បរិសុទ្ធ, សុទ្ធ ។ - **សាលិតណ្ឌុល-នាឡិ** ន. នាឡិនៃអង្ករនៃស្រូវសាលីដ៏ស្អាត, -ដ៏សុទ្ធ ។

**សុធម្មា** អ.ន. នាងសុធម្មា ។ **ទេវសភាសុធម្ម** គុ. ក្រុកដស្មើ ដោយមេវសភាឈ្មោះសុធម្មា ។

**សុធា** ន. ( សុធ+អ+អា_ឥ. ) កំបោរ, បាយអរ; គុ. ស្អាត ។ **បរិកម្មកត** គុ. មានបរិកម្មដោយបាយអរធ្វើហើយ ។ **មត្តិកលេបន** ន. លាបឬបូកដោយបាយអរនិងដីស្អិត, បូកដោយបាយអរ ។ **ភោជនរស** ចុំ. រសនៃសុធាភោជន, រសនៃភោជនដ៏ស្អាត ។

**សុធោត** គុ. ( សុ+ធុ+ត ) ដែលបុគ្គលខាត់ល្អហើយ, លាងល្អហើយ ។ **មណិខណ្ឌមិវ** ន. ដូចជាដុំកែវមណីដែលបុគ្គលខាត់ល្អហើយ ។

**សុនខ** ចុំ. សុនខ, ឆ្កែ ។ **បរិវុត** គុ. គឺឆ្កែចោមរោមហើយ ។ **លុទ្ទក** ចុំ. ព្រានអ្នកបញ្ចើរនូវឆ្កែ, ព្រានអ្នកលែងនូវឆ្កែ, ព្រានឆ្កែ ។ ឥ. **សុនខី** ។

**សុន្ទរ** គុ. [ សុ+ទរ+អ ] ល្អ ។ **តរ** គុ. ល្អជាង, ល្អវិសេស ។

**សុនិទ្ទិដ្ឋ** គុ. [ សុ+និ+ទិស+ត ] ដែលព្រះអង្គសំដែងល្អហើយ ។

**សុនិបុណ** គុ. [ សុ+និ+បុណ+អ ] ល្អិតល្អ, ល្អិតផង, ល្អិតណាស់ ។

**សុនិម្មល** គុ. [ សុ+និ+មល ] មានមន្ទិលចេញហើយដោយល្អ, ប្រាសចាកមន្ទិលដោយល្អ ។

**សុបគ្គហិត** គុ. [ សុ+ប+គហ+ឥ_អា.+ត ] ដែលខ្លួនផ្គងល្អហើយ ។





**សុបញ្ញត្ត** គុ. [ សុ+ប+ញប+ត ] ដែល... តាក់តែងល្អហើយ, ក្រាលល្អហើយ ។

**សុបដិជគ្គិត** គុ. [ សុ+បដិ+ជគ្គ+ឥ_អា.+ត ] ដែល... ថែទាំល្អហើយ, ចិញ្ចឹមបម្រុងល្អហើយ, សម្អាតល្អហើយ, បោសសម្អាតល្អហើយ ។

**សុបដិបន្ន** គុ. [ សុ+បដិ+បទ+ត ] ប្រតិបត្តិល្អហើយ, ប្រតិបត្តិហើយដោយប្រពៃ ។

**សុបណ្ណ** ចុំ. គ្រុឌ (ដូច **សុវណ្ណ**, វេនតេយ្យ) ។

**សុបតិ** ? [ សុប+អ+តិ_វ. ] ដេក, ដេកលក់ ។

**សុបន** នចុំ. ( សុប+យុ ) កិ.ដេកលក់ ។

**សុប្បពុទ្ធ** គុ. [ សុ+ប+ពុធ+ត ] ភ្ញាក់ល្អហើយ, ភ្ញាក់ហើយដោយប្រពៃ ។ អ.ន. សាក្យៈឈ្មោះសុប្បពុទ្ធ ។ **កុដ្ឋី** គុ. បុរសមានរោគឃ្លង់ឈ្មោះសុប្បពុទ្ធ ។

**សុប្បរូបលាភិ** គុ. [ សុប្ប+រូបលាភ+អាវិ ] (គ្រឿងឧបករណ៍) មានចង្កេះនិងរវៃស្រួលជាដើម ។

**សុបរិសំវុត** គុ. [ សុ+បរិ+សំ+វុ+ត ] សង្រួមល្អហើយ ។

**សុប្បសន្ន** គុ. [ សុ+ប+សទ+ត ] ជ្រះថ្លាល្អហើយ ។

**សុប្បារកបដ្ឋន** នចុំ. [ សុប្បារក+បដ្ឋន ] កំពង់ឈ្មោះសុប្បារកៈ ។

**សុបិន** នចុំ. [ សុប+ឥន ] កិ.យល់សប្តិ, សេចក្តីយល់សប្តិ; រ៉. **សុបនំ**

> សុបិនំ, សុបិយកេតិ ចា> សុបិនំ ។

**សុបិហិតទ្វារ** គុ. [ សុបិហិត+ទ្វារ ] មានទ្វារបិទល្អហើយ ។

**សុបុប្ផិត** គុ. [ សុ+បុប្ផ+ឥ.ភ.+ត ] ដែលរីកល្អហើយ ។

**សុបោថិត** គុ. [ សុ+ពោធ ឬ បុថ+ឥ.ភ.+ត ] ដែល...វាយល្អហើយ, ...វាយខ្លាំងហើយ, ...វាយដំណំហើយ ។

**សុផុស្សិត** គុ. [ សុ+ផុស+ឥ+ឥ.ភ.+ត ] ដែលជិតល្អហើយ, ដែលស្និទ្ធជិត ។

**សុពច** គុ. [ សុ+វច+អ ] ដែលគេប្រដៅបានដោយងាយ, ដែលគេស្តីបានដោយងាយ; វិ. សុដ្ឋុ វុច្ចតីតិ> សុព្វចោ ឬ សុវ-ចោ ។

**សុវុដ្ឋិ** ឥ. [ សុ+វុដ្ឋិ ] ភ្លៀងស្រួល, ភ្លៀងល្អ ។ -**ទុវុដ្ឋិភាវ** ពុ. ភាវៈនៃភ្លៀងស្រួលនិងភ្លៀងមិនស្រួល ។

**សុភ** គុ. [ សុភ+អ ] ល្អ, ស្អាត ។

**សុភានុបស្សី** គុ. [ សុភ+អនុ+ទិស+ណី ] អ្នកមានតិ.ឃើញរឿយៗ នូវអារម្មណ៍ថាល្អជាប្រក្រតី; វិ. សុភំ អនុបស្សិតុំ សីលមស្សាតិ> សុភានុបស្សី ។

**សុភាវិត** គុ. [ សុ+ភូ+ឥ.ភ.+ត ] ដែល...ចម្រើនល្អហើយ, ...អប់រំល្អហើយ ។

**សុភាសិត** គុ. [ សុ+ភាស+ឥ.ភ.+ត ] ដែល...សម្តែងល្អហើយ ។



**សុភិក្ខ** ឥ. [ សុ+ភិក្ខា ] ភិក្ខា (បាយ) គឺបុគ្គលបានដោយងាយ; វិ. សុលភា ភិក្ខា> សុភិក្ខា ។ គុ. មានបាយគឺបុគ្គលបានដោយងាយ; វិ. សុលភា ភិក្ខា យេន សោ> សុភិក្ខោ ។

**សុមនបុប្ផ** នពុំ. [ សុមន+បុប្ផ ] ផ្កាម្លិះ ។

**សុមនមកុល** នពុំ. [ សុមន+មកុល ] ផ្កាម្លិះក្រពុំ, ផ្កាម្លិះនោប ។

**សុយុត្ត** គុ. [ សុ+យុជ+ត ] ដែលបុគ្គលប្រកបល្អហើយ ។

**សុរ** គុ. [ សុ+រ ] ក្លៀវក្លា, អង់អាច ។

**សុរត្តទុបដ្ដ** នពុំ. [ សុរត្ត+ទុបដ្ដ ] សំពត់មានជាន់ពីរដែលបុគ្គលជ្រលក់ល្អហើយ (សុរត្ត<សុ+រញ្ជ+ត) ។

**សុរភិគន្ធវាសិត** គុ. [ សុរភិ+គន្ធ+វាសិត ] ដែលបុគ្គលអប់ហើយដោយគ្រឿងមានក្លិនក្រអូប ។

**សុរា** ឥ. [ សុ+រ+អា.ឥ. ] សុរា, ស្រា ។ -**ឆណ** ពុ. មហោស្រព គឺបុគ្គលគប្បីលេងព្រោះសុរា ។ -**បានដ្ឋាន** នពុំ. ទីជាទីផឹកនូវសុរា ។ -**បុណ្ណ** គុ. ដ៏ពេញហើយដោយសុរា ។ -**មទមត្ត** គុ. អ្នកស្រវឹងហើយដោយសេចក្តីស្រវឹងព្រោះសុរា ។

**សុរិយ** ពុ. [ សុរ+ឥយ ] ព្រះអាទិត្យ (វិ. លោកានំ សុរភាវំ ជនេតីតិ> សុរិយោ) ។

**សុរិយុគ្គមន** នពុំ. [ សុរិយ+ឧគ្គមន ] កិ.រះឡើងនៃព្រះអាទិត្យ, ជាទីរះឡើងនៃព្រះអាទិត្យ ។

**សុលទ្ធ** គុ. [ សុ+លភ+ត ] គឺ...បានហើយដោយស្រួល ។

**សុលភ** គុ. [ សុ+លភ+អ ] ដែល...បានហើយដោយល្អ, ...គប្បីបានដោយស្រួល ។

**សុរ, សុរីក** ពុ. [ សុ+អ, ឧបែសុ>ឧរ ] សោក ឱ. **សុណាតីតិ> សុរោ** ។

**សុវច** គុ. [ សុ+វច+អ ] ដែលបុគ្គលប្រដៅបានដោយងាយ, ...ស្តីផាបានដោយងាយ; ឱ. **សុវច្ចំ ឧបុត្តីតិ> សុវចោ** ។

**សុវណ្ណ** នាម. [ សុ+វណ្ណ ] មាស; គុ. មានពណ៌ល្អ, មានសម្បុរល្អ ។ - **កដច្ឆុ** នាម. វែកដែលគេធ្វើដោយមាស, វែកមាស ។ - **ការ** ន. បុគ្គលអ្នកធ្វើនូវមាស, ជាងមាស ។ - **កេយូរ** ន. សង្វារជាវិការៈនៃមាស ។ - **កោសក** ន. ស្រោមជាវិការៈនៃមាស ។ - **យដ្ឋិ** ន. ដងជាវិការៈនៃមាស ។ - **វិចិត្រ** គុ. ដែលវិចិត្រដោយមាស ។ ល ។

**សុវិភត្ត** គុ. [ សុ+វិ+ភជ+ត ] ដែលបុគ្គលចែកល្អហើយ, ...ចែកហើយដោយល្អ ។

**សុវិហីន** គុ. [ សុ+វិ+ហា+ត ] សាបសូន្យហើយ, សូន្យហើយ ។

**សុសញ្ញត** គុ. [ សុ+សំ+យម+ត ] ដែល... សង្រួមល្អហើយ ។

**សុសមារទ្ធ** គុ. [ សុ+សំ+អា+រភ+ត ] ដែលប្រារព្ធល្អហើយ ។

**សុសមាហិត** គុ. [ សុ+សំ+អា+ធា+ត ] អ្នកមានចិត្តតាំងមាំហើយ តម្កល់មាំហើយ ។



**សុសម្បវេទិយ** គុ. [ សុ+សុ+វេទិយ ] គឺ...គប្បីល្អប់បានដោយងាយ ។

**សុសំវិហិត** គុ. [ សុ+សំ+វិ+ធា+ត ] ដែល...ចាត់ចែងល្អហើយ ។

**សុសំវុត** គុ. [ សុ+សំ+វុ+ត ] អ្នកសង្រួមល្អហើយ ។

**សុសាន** នាម. [ ឆវ+សយន, ឆវ>សុ, សយន>សាន ] ទីជាទីដេកនៃសព (ស្មសាន, ព្រៃស្មសាន) ។ - **គោបក** នាម. អ្នកគ្រប់គ្រងនូវព្រៃស្មសាន, អ្នកដែលរក្សានូវព្រៃស្មសាន ។ ឝ. **សុសានគោបិកា** ។ - **សាមន្ត** ន. ទីជិតនៃ... ។

**សុសិក្ខិត** គុ. [ សុសុ+ឈ+ជ...+ក្ខ ] ស្ងប់ហើយ, ស្ងៀមស្ងាត់ហើយ, ស្ងាត់ហើយ, ទំហើយ ។

**សុសិរ** គុ. [ សុសិ+រ ] ប្រហោងប្រហែង, ប្រហោង; ឱ. **សុសិ យស្ស អត្ថីតិ> សុសិរោ (វុក្ខោ)** ។

**សុស្សូសា** គុ. [ សុសុ+សាស+អ ] ការប្រព្រឹត្តនូវសំឡេងជាសុភ ។

**សុស្សោណី** ភា. ន. គុ. [ សុ+សោណិ ] (ស្ត្រី) អ្នកមានត្រគាកល្អ, អ្នកមានត្រគាកល្អ (មានត្រគាកពីគាត់ផ្ចិតដល់ត្រគាកទាំងសងខាង ឬស្ត្រីអ្នកមានត្រគាកពីកណ្ដាលក៏បាន); ឱ. **សុន្ទរា សោណិ យស្សា សា> សុស្សោណី** ។

**សុហជ្ជ** នាម. [ សុហទយ+ណ្យ ] ភាវៈនៃបុគ្គលអ្នកមានហឫទ័យល្អ (មិត្តសម្លាញ់); ឱ. **សុហទយស្ស ភាវោ> សុហជ្ជំ** ។

**សុហិត** គុ. បានប្រយោជន៍ដោយល្អ, ឆ្អែតហើយ, ស្កប់ស្កល់ហើយ ។

**សុហុជ្ជុ** គុ. [ សុ+ឧជុ, ចុះប.រា. ] អ្នកមានចិត្តត្រង់, អ្នកមានចិត្តស្លូតត្រង់ ។

**សូករ** ពុ. ជ្រូក ។ -**បោតក** ពុ. កូននៃជ្រូក ។ ឥ. -**បោតិកា** ។ -**រវ** ន. សម្រែកនៃជ្រូក, សម្រែកដូចជាសម្រែកនៃជ្រូក ។

**សូករិក** ន. [ សូករ+ណិក ] ព្រានជ្រូក (បា. សូករេ ហន្ត្វា ជីវតីតិ> សូករិកោ) ។

**សូចិ** ឥ. [ សុច+ឥ ] ម្ជុល (បា. សូចេតិ បកាសេតីតិ> សូចិ) ។ -**កម្ម** នពុ. កម្មគឺបុគ្គលធ្វើដោយម្ជុល ។ -**បាសក** ន. រន្ធនៃម្ជុល, ច្រមុះនៃម្ជុល ។

**សូប** ពុ. ឬ នពុ. [ សុ+ប ] ឈ្មោះស្លាបព្រាបាយដែលគេប្រើដីក ដើម្បីប្រយោជន៍ដល់សេចក្ដីសុខ (សម្លទឹក ឬម្ហូបទឹក); បា. សុខ-ភាយ បាតព្វោ> សូបោ, សរតិ រុចិ ជនេតីតិ> សូបោ ។ -**ព្យញ្ជន** នពុ. សម្លនិងសម្លគោក (សម្លណាគោកៗ ឬគ្រឿងគ្មានទឹកហៅថាព្យញ្ជនៈទាំងអស់) ។ -**វិកតិ** ឥ. គឺ.ធ្វើឱ្យប្លែកនៃសម្ល, សម្លដែលបុគ្គលធ្វើឱ្យប្លែក, សម្លប្លែកបែប ។

**សូបេយ្យ** នពុ. [ សូប+ឯយ្យ ឬណេយ្យ ] វត្ថុជាប្រយោជន៍ដល់សម្ល (គ្រឿងសម្ល); បា. សូបស្ស ហិតំ> សូបេយ្យំ ។

**សូយិត្ត** គុ. [ សុ+ឈាយ+ឥ.រា.+ត្ត.អដ្ឋ. ] ឆ្អិនហើយ ។



**សូរ** គុ. [ សូរ+អ ] ក្លៀវក្លា, អង់អាច ។ -**ភាព** ពុ. ភាពក្លៀវក្លា ។ -**ពជ្ជិត** គុ. ដែលមនុស្សក្លៀវក្លាតំរាបហើយ ។

**សូល** នពុ. [ សូល+អ ] ឈើអណ្ដោត, ដែកអណ្ដោត; ចម្រូង ឬចម្រូងដែក; ឈើស្នូល ឬឈើស្នូល ។ -**កោដិ** ឥ. ចុងនៃ... ។ -**អគ្គ** ចុងនៃ... ។

**សេក្ខ** ពុ. [ សិក្ខ+ណ ] អ្នកសិក្សានូវសិក្ខា ៣ (សេក្ខបុគ្គល); បា. តិស្សោ សិក្ខា សិក្ខន្តីតិ> សេក្ខា ។ ប្រើជា សេខ ក៏បាន ។

**សេដ្ឋ** គុ. [ បសត្ថ+ឥដ្ឋ, បសត្ថ>ស ] ប្រសើរ, ប្រសើរបំផុត; បា. អយមេតេសំ អតិសយេន បសត្ថោតិ> សេដ្ឋោ ។ -**ធម្ម** ន. ព្រះភាវៈនៃព្រះនិព្វាននោះជាធម្មជាតិប្រសើរ ។

**សេដ្ឋី** ពុ. សេដ្ឋី, មនុស្សអ្នកមានទ្រព្យ ។ -**ដ្ឋាន** នពុ. ទីនៃសេដ្ឋី, តំណែងនៃសេដ្ឋី ។

**សេត** ឬ **សេតក** គុ. ស, មានពណ៌ស ។ -**ឆត្ត** នពុ. ឆត្រស, ស្វេតឆត្រ ។

**សេតិ** កិ. [ សី+អ+តិ.វ. ] ដេក, រមែងដេក ។

**សេតុ** នពុ. [ សិ+តុ ] ស្ពាន (បា. សិនោតិ ពន្ធតិ បារិមតីរំ ឯតេនាតិ> សេតុ) ។ -**ឃាតវល** ពុ. កំណាត់នៃកិ.សម្លាប់នូវបាបធម៌ដោយស្ពានគឺអរិយមគ្គ ។

**សេទ** ពុ. [ សិទ+ណ, ទ>ទ ] ញើស (បា. សេទតិ បច្ចតីតិ> សេទោ) ។

- កិលិន្ន គុ. សើមស្រាំងហើយដោយញើស ។ - តិន្ត គុ. ទទឹកដោយញើស ។

**សេន** ពុ. [ សី ឬ ស្យៃ+ន ] សត្វខ្លែង ។

**សេនាសន្តជ្ជី** គុ. [ សេន+អសន្តជ្ជ ] អ្នកពិនព្រួតអរព្រួយហើយដោយរាំងសម្បត្តិជារបស់ខ្លួន ។ សេន<ស+នា.វិ. ។

**សេនាសន** ឧពុ. [ សេន+អាសន ] ទីជាទីដេកនិងទីជាទីអង្គុយ (សេន<សី+យុ = វិ. សេតិ ឯត្ថាតិ> សេនំ ។ អាសន <អាស+យុ = វិ. អាសតិ ឯត្ថាតិ> អាសនំ) ។

**សេបណ្ណិ** ឥ. ដើមធំបក់ ។

**សេយ្យ** គុ. [ បសត្ថ+ឥយ, បសត្ថ>ស ] ប្រសើរ, ប្រសើរលើសវិសេស (ឱ. ដូច សេដ្ឋោ) ។

**សេយ្យថា** និ. ដូចជា, ប្រៀបដូចជា, យ៉ាងណា, យ៉ាងណាមិញ,... ។

**សេយ្យសិ** គិ. [ សេយ្យ+អ+សិ.វ. ] ពោលចុះ,ផង្រួះ ។

**សេយ្យា** ឥ. [ សី+យ ] គឺ.ដេក, ពិដេក, ជាទីដេក (ឱ. សយន្តិ អស្សន្តិ> សេយ្យា) ។

**សេល** ពុ. [ សិលា+ណ ] តំបន់ថ្ម (ភ្នំ); វិ. សិលានំ រាសិ> សេលោ ។

**សេវក** គុ. [ សេវ+ណ្វុ ] អ្នកសេព, អ្នកសេពគប់; វិ. សេវតីតិ> សេវកោ ។



**សេវិត្តិ** គិ. [ សេវ+អ+តិ.វ. ] សេព, សេពគប់, គប់រក ។

**សេវាល** ពុ. [ សី+អាល ] សារាយ, ចាយហ (ឱ. ឧទកំ សេវតីតិ> សេវាលោ) ។ - បរិយោនទ្ធ គុ. គឺសារាយរួបរឹតហើយ, ព័ទ្ធព័ទ្ធហើយ ។

**សេស** គុ. [ សិស+ណ ] សេសៈ, សល់ ។ - ភាវ ន. ការដ៏សេស ។

**សេសេត្វា** អ. [ សិស+ណេ+ត្វា ] ឱ្យសេសសល់ហើយ, ឱ្យសល់ហើយ ។

**សេហិ** គិ. [ សី+អ+ហិ.ក. ] ចូរដេក ។

**សោក** ពុ. [ សុច+ណ ] សេចក្តីសោក, កិ.សោក; វិ. សុចនំ> សោកោ ។ - បរេត គុ. គឺសេចក្តីសោកគ្របសង្កត់ហើយ ។ បរេត<បរ+ឥ+ត = ប្រព្រឹត្តទៅក្នុងខាងមុខ ។

**សោចតិ** គិ. [ សុច+អ+តិ.វ. ] សោក, សោយសោក, សៅសោក, សោកស្តាយ ។

**សោចន** ឧពុ. [ សុច+យុ ] កិ.សោក, ជាទីសោក, ជាទីសោយសោក ។

**សោណ្ឌ** ពុ. [ សោណ្ឌ+ណ ] អ្នកលេង, រោងស្រា, ប្រមោយដើរ ។

**សោណ្ឌិ** ឥ. [ សោណ្ឌ+ឧ+ឥ ] ត្រពាំង, ត្រពាំងថ្ម ។

**សោត** ឧពុ. [ សុ+ត ] អវយវៈជាគ្រឿងស្តាប់ (ត្រចៀក, ក្រវែល, ខ្សែ; វិ. សុណាតិ ឯតេនាតិ> សោតំ ។

**សោតាបន្ន** គុ. [ សោត+អាបន្ន ] អ្នកដល់ហើយនូវសោតៈ ។

**សោត្ថិ** ន. សួស្តី, សេចក្តីសួស្តី ។ . **ភាវ** ន. ភាវៈនៃសួស្តី, ..នៃអ្នកមានសួស្តី ។

**សោធន** នពុំ. [ សុធ+យុ ] កិ.ជម្រះ, កិ.សម្អាត ។

**សោធិត** គ. [ សុធ+ណេ+អិត្ត.វ. ] ជម្រះ, សម្អាត, ឱ្យស្អាត ។

**សោបាណ** ពុំ. ជណ្ដើរ ។ . **បាទមូល** ន. ប្រទេសជាទីតាំងនៃជើងនៃជណ្ដើរ, ទីជិតនៃជើងនៃជណ្ដើរ ។

**សោភគ្គប្បត្ត** គុ. [ សោភគ្គ+បត្ត ] ដល់ហើយនូវចំណែកដ៏ល្អ, ដល់ហើយនូវសិរីដ៏លើស, ..ដ៏ប្រសើរ ។

**សោភតិ** គ. [ សុភ+អ+តិ.វ. ] ល្អ, លម ។

**សោមនស្ស** នពុំ. [ សុមន+ណ្យ ] ភាវៈនៃបុគ្គលមានចិត្តល្អ ឬភាវៈនៃចិត្តល្អ; វិ. **សុមនស្ស ភាវោ> សោមនស្សំ** ។ . **សហគត** គុ. ទៅព្រមរួមជាមួយសោមនស្ស, ប្រព្រឹត្តទៅព្រមរួមជាមួយ..., ប្រកបដោយ... ។

**សោរត** គុ. [ សុ+រម+ត ] ជាអ្នកត្រេកអរក្នុងកម្មដ៏ល្អ, ជាអ្នកស្ងប់ ។

**សោវណ្ណមយ** គុ. [ សុវណ្ណ+មយ ] ជាវិការៈនៃមាស, គឺបុគ្គលធ្វើហើយដោយមាស, សម្រេចហើយដោយមាស ( វិការត្ថិត, បកតត្ថិត, និប្ផន្នត្ថិត ) ។



**សោស្សាម** គ. [ សុ+អ+ស្សាម.ភ. ] នឹងស្ដាប់, នឹងឮ ។

**សោសានិក** គុ. [ សុសាន+ណិក ] អ្នកនៅក្នុងព្រៃស្មសាន; វិ. **សុសានេ វសតីតិ> សោសានិកោ** ។

**សោឡស** ប.សំ. ដប់ប្រាំមួយ (១៦) ។ . **អង្គុលិកណ្ណក** ន. មានបន្ទាមានធ្នាប់១៦ជាប្រមាណ, មានបន្ទាប្រកបដោយធ្នាប់១៦ ។

**សំឃិក** ឬ **សង្ឃិក** គុ. [ សំឃ+ណិក ] ជារបស់នៃសង្ឃ; វិ. **សំឃស្ស សន្តកំ> សំឃិកំ** ។

**សំយោម** គ. [ សំ+យម+អ+ភិ.ប., ឧបមភិ.ប. ] ចូរសង្រួម,... ។

**សំយុត្ត** គុ. [ សំ+យុជ+ត ] ប្រកបព្រមហើយ ។

**សំយោគ** ពុំ. [ សំ+យុជ+ណ ] កិលេសជាគ្រឿងប្រកបព្រម; វិ. **សំយោជេតិ ឯតេនាតិ> សំយោគោ** ។

**សំយោជន** នពុំ. [ សំ+យុជ+យុ ] កិលេសជាតជាគ្រឿងប្រកបព្រម; វិ. **សំយោជេតិ ឯតេនាតិ> សំយោជនំ** ។ . **សំសគ្គលគ្គ** គុ. អ្នកជាប់នៅហើយក្នុងសំយោជនធម៌និងសំសគ្គធម៌ ។

**សំវច្ឆរ** ពុំ. ឬ នពុំ. [ សំ+វស+ឆរ ] ឆ្នាំ (វិ. **សំវសន្តិ ឯត្ថាតិ> សំវច្ឆរោ**) ។

**សំវឌ្ឍ** គុ. [ សំ+វឌ្ឍ+អ ] ចម្រើនព្រមហើយ ។

**សំវត្តតិ** គ. [ សំ+វត្ត+អ+តិ.វ. ] ប្រព្រឹត្តទៅព្រម ។

**សំវរ** ពុំ. [ សំ+វរ+អ ] កិ.សង្រួម, កិ.រាំង; វិ. **សំវរណំ>**

សំវរោ ។ - ករណ នបុ. កិ.ធ្វើនូវសេចក្ដីសង្រួម ។

**សំវាស** បុ. [ សំ+វស+ណ ] កិ.នៅរួម; ឱ. **សំវសនំ > សំវាសោ** ។

**សំវិគ្គមានស** គុ. [ សំវិគ្គ+មានស ] មានចិត្តស្លុតហើយ, មានចិត្តតក់ស្លុតហើយ (សំវិគ្គ<សំ+វិជ+ត) ។

**សំវិជ្ជន្តិ** កិ. [ សំ+វិជ+យ+អន្តិ.វ. ] ភេទព្រួយ, រំភើបភេទរួប ។

**សំវិទហិ** កិ. [ សំ+វិ+ធា+អ+ហិ.អជ្ជ. ] ចាត់ចែងហើយ ។

**សំវិភាគ** នបុ. [ សំ+វិ+ភជ+ណ ] កិ.បែងចែក, កិ.ចែករំលែក ។

**សំវេគ** បុ. [ សំ+វិជ+ណ ] សេចក្ដីសង្វេគ, សេចក្ដីតក់ស្លុត ។ - ជាត គុ. មានសេចក្ដីសង្វេគកើតហើយ ។

**សំវេគី** គុ. [ សំវេគ+ឦ ] អ្នកមានសេចក្ដីសង្វេគ ។

**សំវេជេត្វា** អ. [ សំ+វិជ+ណេ+ត្វា ] ឲ្យសង្វេគហើយ, ឲ្យតក់ស្លុតហើយ ។

**សំសគ្គ** នបុ. [ សំ+សជ+អ ] កិ.ជាប់ជំពាក់, កិលេសជាគ្រឿងជាប់ជំពាក់; ឱ. **សំសគ្គំ> សំសគ្គោ** ។

**សំសដ្ឋ** គុ. [ សំ+សជ+ត ] ច្រឡំហើយ, ច្រឡូកច្រឡំហើយ, ច្រឡំបល់ហើយ, លាយឡំហើយ ។

**សំសរន្ត** គុ. [ សំ+សរ+អន្ត ] កាលអន្ទោលទៅ ។

**សំសរិត្វា** អ. [ សំ+សរ+ឥ.អា.+ត្វា ] អន្ទោលទៅហើយ ។



**សំសន្ទេត្វា** អ. [ សំ+សន្ទ+អ+ត្វា ] សន្ទនាគ្នាហើយ, ប្រៀបធៀបហើយ, ផ្ទៀងផ្ទាត់ហើយ ។

**សំសារ** បុ. [ សំ+សរ+ណ ] លោកជាទីអន្ទោលទៅនៃសត្វ (សង្សារ); ឱ. **សំសារន្តិ ឯកាគេ> សំសារោ** ។ - **វដ្ដ** ន. វដ្ដៈគឺសង្សារ ។

**សំសិព្វន្តិ** កិ. [ សំ+សិវុ+យ+អន្តិ.វ. ] ដេរព្រម, ចាក់ស្រែះ ។

# ហ

ហញ្ញតិ គិ. [ហន+អ+តិ.វ., ន+ត>ញ្ញ] បៀតបៀន, ក្តៅក្រហាយ ។

ហដ្ឋ គុ. [ហដ+ត] រីករាយហើយ ។ . ពហដ្ឋ គុ. រីករាយហើយ, ត្រេកអរហើយ ។

ហតចក្ខុ គុ. [ហត+ចក្ខុ] មានចក្ខុសាបសូន្យហើយ, មានចក្ខុគឺភ្នែក កំចាត់បង់ហើយ ។

ហត្ថកម្ម នបុំ. [ហត្ថ+កម្ម] កម្មគឺបុគ្គលគេប្រើធ្វើដោយដៃ, ហត្ថកម្ម ។ . មូល នបុំ. ជាតម្លៃនៃហត្ថកម្ម ។

ហត្ថកីឡាបនាទិ គុ. [ហត្ថ+កីឡាបន+អាទិ] (វិការៈ) មានកិ. ញុំាង...ឱ្យលេងដោយដៃជាដើម ។

ហត្ថគត គុ. [ហត្ថ+គត] ទៅហើយក្នុងដៃ, (នៅក្នុងដៃ, នៅក្នុងកណ្ដាប់ដៃ) ។

ហត្ថាជានិយ ពុំ. [ហត្ថ+អាជានិយ] ដំរីអាជានេយ្យ (ប្រើជា ហត្ថាជានេយ្យ ក៏បាន) ។

ហត្ថី ពុំ. [ហត្ថ+ឦ] សត្វមានដៃ (ដំរី); វិ. ហត្ថោ យស្ស អត្ថីតិ> ហត្ថី ។ ឥ. ចុះឥនីបច្ច័យជា ហត្ថិនី ដំរីញី ឬ មេដំរី ។ . កន្តវីណា ឥ. ពិណជាទីត្រេកអរនៃដំរី, ពិណជាទីញុំាងដំរីឱ្យត្រេកអរ ។ . កលភ ពុំ. ដំរីស្ទាវ ។ . ក្ខន្ធវរគត គុ. ទៅហើយលើកនៃដំរីដ៏ប្រសើរ, ឋិតនៅលើកនៃ... ។ . ឆាប ពុំ. កូនដំរី ។ . ជេដ្ឋក គុ. ដំរីជាធំ, ដំរីពាលូង ។ . នាគ ពុំ. នាគគឺដំរី, ដំរីដ៏ប្រសើរ ។ . ពោតក ពុំ. កូននៃដំរី ។ . រូប នបុំ.





រូបនៃដំរី, រូបប្រៀបនៃដំរី ។ . លេណ្ឌ ន. គូថនៃដំរី, អាចម៍នៃដំរី ។ . លិង្គសកុណ ពុំ. សត្វស្លាបហត្ថិលិង្គ, សត្វស្លាបមានភេទដូចជាភេទនៃដំរី ។ . វាហន នបុំ. វាហនៈគឺដំរី ។

ហតាវកាស គុ. [ហត+អវកាស] អ្នកមានឱកាសសាបសូន្យហើយ,... ។

ហទយនិស្សិត គុ. [ហទយ+និស្សិត] អាស្រ័យហើយនូវហឫទ័យ ។

ហន្ត្វា អ. [ហន+ត្វា] សម្លាប់ហើយ ។

ហន្តិ គិ. [ហន+អ+តិ.វ.] បៀតបៀន, សម្លាប់ ។ ប្រើជា ហនតិ ក៏បាន ។

ហន្ទ និ. ណ៎, ហើយចុះ,... ។

ហនាបេយ្យ គិ. [ហន+ណាបេ+ឯយ្យ.ត.] គប្បីឱ្យបៀតបៀន, -ឱ្យសម្លាប់ ។

ហនុកដ្ឋិក ន. [ហនុក+អដ្ឋិ+ក] ឆ្អឹងនៃចង្កា ។

ហនេយ្យ គិ. [ហន+អ+ឯយ្យ.ត.] គប្បីបៀតបៀន, គប្បីសម្លាប់ ។

ហយ ពុំ. [ហយ+អ] សេះ វិ. ហយតិ សីឃំ គច្ឆតីតិ> ហយោ ។

ហរ គិ. [ហរ+អ+ហិ.ប., លុបហិ.ប.] ចូរនាំទៅ ។

ហរតិ គិ. [ហរ+អ+តិ.វ.] នាំទៅ, រមែងនាំទៅ ។

ហរាបេយ្យាសិ គិ. ( ហរ+ណាបេ+ឯយ្យាសិ.គា. ) គប្បីញុំាង...ឱ្យនាំទៅ, គប្បីបន្ទួយ ។

ហរាបេន្ត គុ. ( ហរ+ណាប+អន្ត, ឯនៃបេ>អាប ) កាលឱ្យនាំ ។

ហរាហិ គុ. ( ហរ+អ+ហិ.ប. ) ចូរនាំទៅ, ចូរបន្ទួយ, ចូរជញ្ជូនទៅ ។

ហរិចន្ទនុស្សទ គុ. ( ហរិចន្ទន+ឧស្សទ ) មានកិ.ព្រោះព្រំដោយខ្លឹមចន្ទន៍លឿង, មានខ្លួនព្រោះព្រំដោយ... ។ ហរិចន្ទន៍ នុ.គឺខ្លឹមចន្ទន៍ក្រហម, ចន្ទន៍ទេស ។

ហរិតបត្ត គុ. ( ហរិត+បត្ត ) មានស្លឹកខៀវ ។

ហរិត្វា អ. ( ហរ+ធ.រក.+ត្វា ) នាំទៅហើយ ។

ហរិតព្វ គិ. ( ហរ+ធ.រក.+តព្វ ) គឺ...គប្បីនាំទៅ ។ - ហរិតព្វក គុ. ខ្ញុំ គឺខ្លួនគប្បីនាំទៅ ។

ហរិតាលមនោសិលា ន. ( ហរិតាល+មនោសិលា ) ថ្មហរិតាលនិងមនោសិលា (ពាក្យទាំងពីរនេះជាឈ្មោះថ្មមានសាច់ទន់ផុយ មានពណ៌លឿង, ពណ៌ស្ពឺ ) ។

ហរិតុបលិត្ត គុ. ( ហរិត+ឧបលិត្ត ) ដែលគួរលាបហើយដោយវត្ថុមានពណ៌ខៀវ ។ ឧបលិត្ត<ឧប+លិប+ត ។

ហរិយន្តិ គិ. ( ហរ+ធ.រក.+យ+អន្តិ.វ. ) គឺ...នាំទៅ ។

ហលាហល គុ. ( ហាល+អហល ) ក្លានិងក្លាដ៏ខ្លាំង, ដ៏ខ្លាំងក្លាក្រៃពេក, ដ៏សាហាវក្រៃលែង ។



ហវេ និ. ដោយពិត... ។ និបាតនេះច្រើនចុះមកជាបទបូរណៈមិនបាច់ប្រែក៏បាន ។

ហសនកេឡិ ន. ( ហសន+កេឡិ ) កិ.ចំអកដោយកិ.សើច ឬកិ.សើចនិងកិ.ចំអក, កិ.សើចចំអក ។

ហសន្តិ គិ. ( ហស+អ+អន្តិ.វ. ) សើច, ញញឹម ។

ហសិ គិ ( ហស+អ+ឦ អជ្ជ. ) សើចហើយ, ញញឹមហើយ ។

ហសិត គុ. ( ហស+ធ.រក.+ត ) កិ.សើចដ៏...សើចហើយ ។ - គីត-នច្ចាទិ គុ. មានកិ.សើច និងកិ.ច្រៀង និងកិ.រាំជាដើម ។ - មត្តការណា ន. ព្រោះហេតុត្រឹមតែកិ.សើច ។

ហានិ ឥ. ( ហា+និ ) សេចក្ដីសាបសូន្យ; វិ. ហាយតេតិ> ហានិ ។

ហាបយេ គិ. ( ហា+ណាបយ+ឯយ្យ.ស. ) គប្បីឱ្យសាបសូន្យ ។

ហាបេតព្វ គិ. ( ហា+ណាបេ+តព្វ ) គឺ...គប្បីឱ្យសាបសូន្យ ។

ហាបេតុ គិ ( ហា+ណាបេ+តុ ) ចូរសាបសូន្យ ។

ហារេត្វា អ. ( ហរ+ណេ+ត្វា ) ញុំាង...ឱ្យនាំទៅហើយ, ឱ្យបន្ទួយចេញហើយ ។

ហាស គុ. ( ហស+ណ ) កិ.សើច, កិ.រីករាយ; វិ. ហសនំ> ហាសោ ។

ហាសយេយ្យ គិ. ( ហស+ណយ+ឯយ្យ.ប. ) ចូរឱ្យរីករាយ ។

ហាសយោគិ ក. [ ហស+ណយ+សុភូមិ_ភ. ] នឹងឲ្យរីករាយ ។

ហាសយិត្វា អ. [ ហស+ណយ+ឥ_អា.+ត្វា ] ឲ្យរីករាយហើយ ។

ហាស្សំ ក. [ ហរ+អ+ស្សំ_ភ. ] នឹងនាំទៅ ។

ហាសេតិ ក. [ ហស+ណេ+តិ_វ. ] ឲ្យរីករាយ ។

ហិ និ. ពិត, មែនពិត,... ។

ហិត គុ. ឬ ន. [ ហិ+ត ] ផលដែលប្រព្រឹត្តទៅតាមសប្បាយដល់ហេតុ (ប្រយោជន៍, សេចក្ដីធំទូលាយប្រសើរ, អប្បមាណ); ឧ. ការណា នាំមក ហិតានុគុណ បច្ចត្តគតិ> ហិតំ ។ _ ការី ន. កម្ពុជា ប្រយោជន៍ ។ _ កាម គុ. អ្នកប្រាថ្នាប្រយោជន៍ ។ _ សុខទ្ធិ គុ. ដែលញុំាងប្រយោជន៍ឲ្យដល់គ្រប់, _ឲ្យសម្រេច ។

ហិត្វា អ. [ ហា+ត្វា, អាទេសហា>ឥ ] លះបង់ហើយ ។

ហិមវន្ត ន. [ ហិម+វន្ត ] ព្រៃហិមវន្ត ឬហិមពាន្ត (ប្រទេស ឬភ្នំព្រៃ មិនសល់ឡើយ) ។

ហិយ្យោ ន. ថ្ងៃម្សិល, ក្នុងថ្ងៃម្សិល ។

ហិរញ្ញ នពុំ. [ ហរ+អញ្ញ, ហរ>ហិរ ] ប្រាក់ ឧ. ឧបមាគិ សព្វាន់ ហិតន្តិ> ហិរញ្ញំ ។

ហិរាហិរ គុ. [ ហិរ+អហិរ ] ឲ្យជាឥស្សរៀកតូចនិងឥស្សរៀកធំ, _បំណែក តូចនិងបំណែកធំ ។



ហិរិ ឥ. [ ហិរិ+ឥ ] សេចក្ដីខ្មាស, សេចក្ដីខ្មើម ឧ. កាយទុច្ចរិតា ធិហិ ហិរិយតិតិ> ហិរិ ។

ហិរិនិសេធ គុ. [ ហិរិ+និសេធ ] អ្នកឃាត់នូវអកុសលវិតក្កៈដោយ ហិរិ ។

ហិរិមា គុ. [ ហិរិ+មន្តុ ] អ្នកមានហិរិ, អ្នកមានសេចក្ដីខ្មាស; ឧ. ហិរិ យស្ស អត្ថិតិ> ហិរិមា ។

ហីន គុ. [ ហា+ឥន, ឥ>ឦ ឬហិ+ន ] ថោកទាប, ដែលថយថោក ។

ហីយោ និ. ( ចូរមើល ហិយ្យោ ) ។

ហីឡេតិ ក. [ ហីឡ+ណេ+តិ_វ. ] មើលងាយ, មើលណាយ ។

ហឹគុច្ចុណ្ណ នពុំ. [ ហិគុ+ចុណ្ណ ] លំអិតនៃដើមហិង្គុ, _នៃជាតិហិង្គុ ។

ហឹសមន ពុំ. [ ហិស+មន ] ចិត្តដែលបៀតបៀន ។

ហឹសតិ ក. [ ហិស+អ+តិ_វ. ] បៀតបៀន ។

ហឹសិត គុ. [ ហិស+ឥ_អា.+ត ] គឺ...បៀតបៀនហើយ ។

ហឹសេយ្យ ក. [ ហិស+អ+ឯយ្យ_សរ. ] គប្បីបៀតបៀន ។

ហុត្វា អ. [ ហុ+ត្វា ] មាន, ជា... ។

ហុត ក. ឬ គុ. [ ហុ+ត ] (យញ្ញៈ) ដែលបុគ្គលបូជាហើយ ។

ហុរំ និ. កាន់លោកដទៃ, ភពដទៃ ។

**ហុរាហុរ៍** ន. [ហុរ+អហុរ] ការភពតូចនិងភពធំ ។

**ហេដ្ឋា** ន. ខាងក្រោម, ក្នុងខាងក្រោម ។ -**អបាយសម្បាបក** គុ. ដែលញ៉ាំងសត្វឱ្យដល់ព្រមនូវ អបាយក្នុងខាងក្រោម ។ -**ឱតរណកាល** ន. កាលដែលចុះក្នុងខាងក្រោម ។ -**បាសាទ** ន. ក្នុងខាងក្រោមនៃប្រាសាទ ។ -**ភាគ** ន. ចំណែកក្នុងខាងក្រោម ។

**ហេដ្ឋាភិមុខ** គុ. [ហេដ្ឋា+អភិមុខ] មានមុខឆ្ពោះទៅក្នុងខាងក្រោម ។

**ហេដ្ឋិម** គុ. [ហេដ្ឋា+ឥម] មានក្នុងខាងក្រោម ឬប្រព្រឹត្តទៅក្នុងខាងក្រោម; វ. ហេដ្ឋា ភវោ បវត្តោ វា> ហេដ្ឋិមោ ។ -**កាយ** ន. កាយមានក្នុងខាងក្រោម ។

**ហេតុ** បុ. [ហិ+តុ] (សភាវៈ) ជាទីតាំងនៃផល ឬជាទីប្រព្រឹត្តទៅនៃផល (ហេតុ); វ. ហិនោតិ បតិដ្ឋា ផលមេត្ថាតិ> ហេតុ, ហិនោតិ បវត្តតិ ផលមេត្ថាតិ វា> ហេតុ ។ -**ប្បភវ** គុ. មានហេតុជាដែនកើតមុន ។ -**សម្បន្ន** គុ. អ្នកដល់ព្រមហើយដោយហេតុ, អ្នកបរិបូណ៌ដោយហេតុ ។

**ហោតព្វំ** កិ. [ហុ+អ+តព្វ-ក., ឧ.ហុ>ឱ] គួរមាន, គួរជា... ។

**ហោតិ** កិ. [ហុ+អ+តិ-វ.] មាន, ជា... ។

**ហោន្ត** គុ. [ហុ+អន្ត] កាលមាន, កំពុងមាន, កាលជា... ។

**ហំស** បុ. [ហន+ស] សត្វហើរទៅកាន់ផ្លូវឆ្ងាយ (ហង្ស); វ. ហន្តិ



អទ្ធានន្តិ> ហំសោ ។ -**ឃាតក** គុ. អ្នកសម្លាប់នូវហង្ស (ឃាតក<ហន+ណ្វុ = វ. ហំសំ ហនតីតិ> ហំសឃាតកោ) ។ -**បោតក** បុ. កូននៃហង្ស ។